**សេចក្តីប្រកាសព័ត៌មាន៖ អង្គភាពនានានៃអង្គការសហប្រជាជាតិមានកង្វល់ពីការចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្សផ្នែកបរិស្ថាននៅកម្ពុជា**

ទីក្រុងបាងកក (៣០ មិថុនា ២០២១) - សិទ្ធិមនុស្ស អ.ស.ប និងកម្មវិធីបរិស្ថានរបស់ អ.ស.ប មានកង្វល់អំពីការឃុំខ្លួនអ្នកការពារសិទ្ធិមនុស្សផ្នែកបរិស្ថាននៅកម្ពុជា។

នៅថ្ងៃទី១៦ ខែមិថុនា សកម្មជនចំនួនបួនរូប ដែលធ្វើការឱ្យអង្គការមាតាធម្មជាតិកម្ពុជា (អឹមអិនស៊ី) ជាអង្គការមូលដ្ឋានមួយ ដែលតស៊ូមតិដើម្បីការពារ និងអភិរក្សបរិស្ថានធម្មជាតិរបស់កម្ពុជា ត្រូវបានចាប់ខ្លួនដោយនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

"យើងកំពុងរស់នៅក្នុងពេលមានវិបត្តិបរិស្ថាន។ សង្គមស៊ីវិលដែលតស៊ូមតិដោយសន្តិវិធី ដើម្បីបរិស្ថានគឺជាដៃគូមួយដ៏សំខាន់ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងឡាយនៃការប្រែប្រួលអាកាសធាតុ ការបាត់បង់ជីវចម្រុះ និងការបំពុលបរិស្ថាន"។ នេះបើតាមប្រសាសន៍របស់ លោក Dechen Tsering នាយកប្រចាំតំបន់នៃកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិប្រចាំនៅអាស៊ី និងប៉ាស៊ីហ្វិក។

យ៉ាងហោចណាស់មានអ្នកការពារសិទ្ធិមនុស្សចំនួន ២៤ រូប ដែលក្នុងនោះមាន ១២ រូប ជាស្ត្រី បច្ចុប្បន្នកំពុងជាប់ឃុំនៅក្នុងប្រទេសកម្ពុជា។

"វាជាការចាំបាច់ ដើម្បីបញ្ឈប់ការប្រើវិធានការដាក់ទណ្ឌកម្មទាំងអស់ ដែលមានជាទម្លាប់ទៅលើសកម្មជនសិទ្ធិមនុស្ស និងសកម្មជនសិទ្ធិបរិស្ថាននៅក្នុងប្រទេសកម្ពុជា។ ការងារសិទ្ធិមនុស្ស និងបរិស្ថានមិនមែនជាបទល្មើសព្រហ្មទណ្ឌនោះទេ"។ នេះបើតាមប្រសាសន៍របស់អ្នកស្រី Cynthia Veliko តំណាងអាស៊ីអាគ្នេយ៍នៃការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិប្រចាំនៅទីក្រុងបាងកក។

អ្នកស្រី Veliko បានមានប្រសាសន៍ថា "យើងជំរុញឲ្យអាជ្ញាធរធានាថាអង្គការសិទ្ធិមនុស្ស និងអង្គការសង្គមស៊ីវិលនានានៅកម្ពុជា អាចធ្វើប្រតិបត្តិការដោយគ្មានការភ័យខ្លាច និងការបំភិតបំភ័យ ហើយសិទ្ធិសេរីភាពរបស់ពួកគេក្នុងបញ្ចេញមតិ សិទ្ធិជួបជុំដោយសន្តិវិធី និងសិទ្ធិចងក្រងសមាគម ត្រូវបានការពារ និងគោរព"។

ការចាប់ខ្លួនសកម្មជននៃអង្គការមាតាធម្មជាតិកម្ពុជា ធ្វើឱ្យមានកង្វល់ជាថ្មីចំពោះលំហរួមតូចសម្រាប់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ដែលជាបញ្ហាមួយបានលើកឡើងដោយអគ្គលេខាធិការ អ.ស.ប កាលពីខែសីហា ឆ្នាំ២០២០ ។

អង្គភាពនានារបស់អង្គការសហប្រជាជាតិ អំពាវនាវឱ្យរដ្ឋាភិបាលកម្ពុជាគោរពតាមការប្តេជ្ញាចិត្តចំពោះសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន រួមទាំងអនុសាសន៍ទាំងឡាយដែលបានធ្វើឡើងដោយគណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងអនុសាសន៍នានាដែលត្រូវបានទទួលយកដោយស្ម័គ្រចិត្តក្នុងកំឡុងពេលត្រួតពិនិត្យជាសកល ដើម្បីធានាសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្ស និងអ្នកការពារបរិស្ថាន ដើម្បីសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិជួបប្រជុំ និងសិទ្ធិចូលរួមក្នុងសមាគមដោយគ្មានការយាយីរំខាន ការតាមឈ្លបមើល ឬការរឹតត្បិតហួសហេតុដទៃទៀត។ ការលើកស្ទួយ និងការការពារសិទ្ធិមនុស្សផ្នែកបរិស្ថាន មិនមែនជាបទល្មើសឡើយ។

ចប់

***សម្រាប់ព័ត៌មានបន្ថែម និងការស្នើសុំព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយ សូមទាក់ទង៖***

*លោក Todd Pitman មន្ត្រីព័ត៌មានប្រចាំតំបន់របស់ OHCHR ៖ +៦៦ ៦៣ ២១៦ ៩០៨០ / todd.pitman@un.org ឬ លោក Wannaporn Samutassadon មន្ត្រីព័ត៌មានជាតិ OHCHR៖ +៦៦ ៦៥ ៩៨៦ ០៨១០ /wannaporn.samutassadong@un.org ឬ លោក Adam Hodge មន្ត្រីព័ត៌មានប្រចាំតំបន់របស់ UNEP៖ +៦៦ ២២៨៨-១២៣០ / adam.hodge@un.org*

***ថេក និងចែករំលែក -***

ទ្វីតធឺ ៖ ***@OHCHRAsia*** *និង* ***@UNEP_AsiaPac***

ហ្វេសប៊ុក៖ ***OHCHRAsia*** *និង* ***UNEPROAP***